ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
ឆ្នាំ ២០១០

ឧបត្ថម្ភដោយគម្រោងទ្រទ្រង់វិស័យអប់រំកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ

ឆ្នាំ ២០១០

# កថាមុខ

ការស្តារនិងការអភិវឌ្ឍវិស័យអប់រំឡើងវិញនៅកម្ពុជាដែលត្រូវបានបំផ្លិចបំផ្លាញដល់កម្រិតសូន្យក្នុងរបបប្រល័យពូជសាសន៍ បានធ្វើឱ្យយើងជួបការលំបាកយ៉ាងខ្លាំង ។ ប៉ុន្តែបច្ចុប្បន្ននេះ វិស័យអប់រំមានសន្ទុះរីកចម្រើនគួរឱ្យកត់សម្គាល់ ។ សាលារៀននិងគ្រូបង្រៀនគ្រប់ភូមិសិក្សាត្រូវបានកសាងនិងធានាបានការរៀនសូត្ររបស់សិស្សានុសិស្សក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។ ទន្ទឹមនឹងការរីកចម្រើននេះ ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើគុណភាព និងសមត្ថភាពធនធានមនុស្ស ដើម្បីឱ្យឆ្លើយតបទៅនឹងសកលភាវូបនីយកម្មអប់រំទាំងនៅក្នុងតំបន់ និងនៅលើសកលលោក។ គ្រូបង្រៀនជាកត្តាមួយ ដែលមិនអាចខ្វះបានក្នុងការអភិវឌ្ឍប្រទេសជាតិ ជាពិសេសគុណភាពអប់រំ ។ តាមរយៈការកែលំអកម្មវិធីសិក្សាចំណេះទូទៅកម្មវិធីបណ្តុះបណ្តាលគ្រូ និងវគ្គបំប៉នសមត្ថភាពដទៃទៀតជាច្រើនយើងនឹងពង្រីកសមត្ថភាពគ្រូបង្រៀនឱ្យដល់កម្រិតអតិបរមា ។ ស្របពេលជាមួយគ្នានេះដែរ ក្រសួងបានខិតខំផ្តួចផ្តើមគំនិតកសាងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននេះឡើង សម្រាប់ជាត្រីវិស័យចង្អុលប្រាប់អ្នកអប់រំទាំងអស់ក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូ ក៏ដូចជាវគ្គវិក្រឹតការនានា ដើម្បីធ្វើបច្ចុប្បន្នភាពសមត្ថភាពគ្រូបង្រៀន ឱ្យស្របតាមយុគសម័យបច្ចេកវិទ្យាព័ត៌មាន និងសង្គម ដោយផ្អែកលើពុទ្ធិ ។

ក្រសួងអប់រំ យុវជន និងកីឡា មានជំនឿយ៉ាងមុតមាំថាស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននេះនឹងជួយជំរុញឱ្យការកសាងជួរគ្រូបង្រៀនដើម្បីធានាបាននូវគុណភាព ជាពិសេសជួយគ្រូបង្រៀនឱ្យមានលទ្ធភាពនិងសមត្ថភាពពេញលេញក្នុងការបង្រៀន និងរៀន ។

ជាទីបញ្ចប់ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះចំពោះគម្រោងទ្រទ្រង់វិស័យអប់រំកម្ពុជា(CESSP) ដែលបានជួយឧបត្ថម្ភទាំងថវិកា និងជំនួយការបច្ចេកទេស ដើម្បីកសាងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននេះឡើង ។ ជាមួយគ្នានេះដែរ ខ្ញុំសូមកោតសរសើរចំពោះស្នាដៃដ៏ល្អប្រពៃរបស់ក្រុមការងារអភិវឌ្ឍន៍ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនក្នុងការខិតខំជំរុញវិស័យអប់រំរបស់យើង ឱ្យរីតតែល្អប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

អ៊ឹម_សិទ្ធី

# មាតិការឿង


| ល.រ | ខ្លឹមសារ | ទំព័រ |
| --- | --- | --- |
| ១- | សេចក្តីផ្តើម ........................................ | ១ |
| ២- | រចនាសម្ព័ន្ធស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន .................. | ៥ |
| ៣- | ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនជាអ្វី? ........................ | ៦ |
| ៤- | គោលបំណង ........................................ | ៦ |
| ៥- | ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនមានផលប្រយោជន៍អ្វីខ្លះ? | ៧ |
| ៦- | ចំណេះដឹងវិជ្ជាជីវៈ.............................................. | ៨ |
| ៧- | ការប្រតិបត្តិវិជ្ជាជីវៈ........................................ | ១១ |
| ៨- | ការសិក្សាវិជ្ជាជីវៈ.............................................. | ១៦ |
| ៩- | សីលធម៌វិជ្ជាជីវៈ .............................................. | ១៩ |

# សេចក្តីផ្តើម

ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពសម្រាប់បម្រើប្រទេសជាតិមិនអាចកាត់ផ្តាច់ចេញពីការអប់រំបានឡើយ ។ វិស័យអប់រំរីកចម្រើន និងមានប្រសិទ្ធភាពទាមទារជាចាំបាច់នូវកម្រិតសមត្ថភាពរបស់គ្រូបង្រៀនដែលក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងយកចិត្តទុកដាក់ថែបំប៉នជាប្រចាំ ។

ជាការពិត ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ វិស័យអប់រំ ក៏ដូចជាវិស័យផ្សេងទៀតដែរត្រូវបានបំផ្លិចបំផ្លាញដល់កម្រិតសូន្យ ទាំងធនធានមនុស្សទាំងមូលដ្ឋានសម្ភារបរិក្ខារ ។

នៅថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៨០ ក្រសួងអប់រំ យុវជន និងកីឡាត្រូវបានបង្កើតឡើងវិញ សាលារៀនគ្រប់កម្រិតសិក្សាក្នុងទូទាំងប្រទេសត្រូវបានបើកទ្វារទទួលសិស្សានុសិស្ស ។ ទន្ទឹមនឹងនេះ ការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនត្រូវបានចាប់ផ្តើមជាបន្ទាន់ដោយមាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការជាអ្នកទទួលខុសត្រូវ ។

ក្នុងស្ថានភាពដ៏លំបាកនេះ ការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនត្រូវបានចាប់ផ្តើមពីការប្រមូលអតីតគ្រូបង្រៀន សិស្ស និស្សិត និងអ្នកមានកម្រិតវប្បធម៌មួយចំនួន ដែលនៅសេសសល់ពីការកាប់សម្លាប់មកបំប៉ន ចិត្ត-គរុកោសល្យ និងវិធីសាស្ត្របង្រៀនរយៈពេលខ្លីនៅតាមសាលាគរុកោសល្យ និងវិក្រឹតការរាជធានី-ខេត្តទាំង១៨ រួចបញ្ជូនទៅកាន់សាលារៀនចំណេះទូទៅក្នុងទូទាំងប្រទេស ។ ជាមួយគ្នានេះដែរ ការបំប៉នមន្ត្រីគ្រប់គ្រងអប់រំក៏ត្រូវបានចាប់ផ្តើមផងដែរតាមរយៈការបើកវគ្គបំប៉នប្រមូលផ្តុំ នៅសាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រងអប់រំដែល "បច្ចុប្បន្នជាវិទ្យាស្ថានជាតិអប់រំ " ។

ចាប់ពីឆ្នាំ ១៩៨៣ ក្រសួងបានសម្រេចឱ្យសាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្តទាំង ១៨ និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម បណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា និងមត្តេយ្យសិក្សារយៈពេលវែងដោយ ចាប់ផ្តើមពីរូបមន្ត 7 +1 រហូតដល់ 12 +2 សម្រាប់ខេត្តរំាលរាប ។ ដោយឡែកសម្រាប់ខេត្តភូមិភាគឦសាន កោះកុង និងតំបន់ដាច់ស្រយាលមួយចំនួន ការបណ្តុះបណ្តាលគ្រូបឋមសិក្សាត្រូវបានចាប់ផ្តើមពីរូបមន្ត 3 +1 និងបច្ចុប្បន្ន 9 +2 និង 12 +2 ។

នៅឆ្នាំ ១៩៨៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៦ត្រូវបានបង្កើតឡើងសម្រាប់បណ្តុះបណ្តាលគ្រូមធ្យមសិក្សា បឋមភូមិដោយផ្តើមពីរូមមន្ត 7+3 រហូតបច្ចុប្បន្ន 12 +2 ។

ដោយឡែកចំពោះការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម បានចាប់ផ្តើមពីឆ្នាំសិក្សា 1980-1981 នៅសាលាគរុវិជ្ជាជាន់ខ្ពស់ "បច្ចុប្បន្នជាសាកលវិទ្យាល័យភ្នំពេញ "ដោយចាប់ផ្តើមពីការបណ្តុះបណ្តាលរយៈពេលខ្លី 4 ខែ 7 ខែ 10 + 3 10 + 4 និងបរិញ្ញា +1 ដែលកំពុងបន្តនៅវិទ្យាស្ថានជាតិអប់រំរហូតដល់បច្ចុប្បន្ន។

ក្នុងស្ថានភាពបែបនេះ យើងឃើញថាគុណភាពនៃការអប់រំមានការប្រែប្រួលមួយកម្រិតគួរឱ្យកត់សម្គាល់ ប៉ុន្តែវានៅមានលក្ខណៈដោយឡែកពុំអាចកំណត់នូវកម្រិតគុណភាពមួយបានសមស្របនៅឡើយ ពោលគឺសមត្ថភាពរបស់គ្រូបង្រៀនពុំស្មើគ្នា ។ ផ្តើមចេញពីនេះដើម្បីឱ្យការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនមានកម្មវិធី និងទិសដៅច្បាស់លាស់ដោយធានាបាននូវគុណភាពសមស្រប ទើបក្រសួងបានកសាងស្តង់ដារនេះឡើង ក្នុងគោលបំណងធ្វើឱ្យគ្រូបង្រៀនយើងមានសមត្ថភាពដល់ស្តង់ដារមួយសមស្របប្រហាក់ប្រហែលនឹងគ្រូបង្រៀនក្នុងតំបន់។

តើស្តង់ដារជាអ្វី ?

ពិតហើយថា ការកំណត់កម្រិតបរិមាណ និងគុណភាពផលិតផលមួយវាអាស្រ័យមួយផ្នែកធំទៅលើបុគ្គល ឬមនុស្សមួយក្រុមដែលគេសន្មតថា "ស្តង់ដារ "។ អ្នកខ្លះប្រើពាក្យស្តង់ដារសម្រាប់កំណត់បរិមាណ។ ឧទាហរណ៍ៈ ធ្វើការ ៧ម៉ោង ក្នុងមួយថ្ងៃ ជាស្តង់ដារមួយ ។ ឯអ្នកខ្លះទៀតប្រើពាក្យស្តង់ដារសម្រាប់កំណត់គុណភាព។ឧទាហរណ៍ៈគ្រូបង្រៀនមានគុណភាពលុះត្រាតែមានចំណេះដឹងលើមុខវិជ្ជាឯកទេសមានទេពកោសល្យក្នុងការបង្រៀន។ ប៉ុន្តែស្តង់ដារគុណភាពពិបាកនឹងកំណត់ណាស់ ពោលគឺវាប្រែប្រួលទៅតាមអាជីព ប្រភេទផលិតផល និងប្រទេសនីមួយៗ ។

ដូច្នេះពាក្យស្តង់ដារត្រូវបានប្រើប្រាស់សម្រាប់កំណត់គុណភាព និងបរិមាណរបស់វត្ថុ ឬសមត្ថភាពរបស់មនុស្សទៅតាមមុខរបរ ឬអាជីពផ្សេងៗគ្នា ។

ការកំណត់ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនពីប្រទេសមួយទៅប្រទេសមួយ ផ្អែកលើកត្តាច្រើនដូចជា កត្តាបច្ចេកវិទ្យា សេដ្ឋកិច្ច សង្គម និងវប្បធម៌។ ដោយឡែកស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជាយើងបានកំណត់ជាបួនសមាសភាគគឺ ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ។ សមាសភាគនីមួយៗ មានអនុសមាសភាគជាច្រើន និងនៅក្នុងអនុសមាសភាគនីមួយៗមានសេចក្តីពណ៌នាស្តង់ដារជាច្រើនបន្តទៀត ហើយនៅក្នុងសេចក្តីពណ៌នាស្តង់ដារនីមួយៗមានបញ្ជាក់ពីសមត្ថភាពលម្អិតតូចៗសម្រាប់ផ្ទៀងផ្ទាត់សមត្ថភាពស្តែងឡើង។

ទោះបីស្តង់ដារបានលើកឡើងពីសមត្ថភាពសំខាន់ៗជាច្រើន តែយើងនឹងជ្រើសរើសយកតែសមត្ថភាពមួយចំនួនដែល យើងចាត់ទុកថា ជាសមត្ថភាពអប្បបរមាប៉ុណ្ណោះ ឯសមត្ថភាពផ្សេងទៀត នឹងត្រូវលើកយកមកបង្ហាញនាពេលអនាគត ។ ជាមួយគ្នានេះ យើងក៏មានជំនឿជាក់ផងដែរថា គ្រូបង្រៀនទាំងអស់មានសមត្ថភាពដល់ស្តង់ដារអប្បបរមាហើយ ។

ឧទាហរណ៍ៈការបង្ហាញពីការប្ដេជ្ញាចិត្តនិងការចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀន។ ឯស្តង់ដារផ្សេងទៀត យើងដឹងថាគ្រូបង្រៀនភាគច្រើនកំពុងធ្វើ។ ឧទាហរណ៍ ៖ ផ្តល់បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យសិស្សរៀនអស់ពីសមត្ថភាព។ ឯស្តង់ដារខ្លះទៀតមានតែគ្រូមួយចំនួនតូចទេ ដែលអាចធ្វើបាន ។ ឧទាហរណ៍ ៖ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យ ដើម្បីធ្វើឱ្យការបង្រៀនមានប្រសិទ្ធភាព។

# រចនាសម្ព័ន្ធស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន

**ឧទាហរណ៍ :**

សមាសភាគ → **១. ចំណេះដឹងវិជ្ជាជីវៈ**

អនុសមាសភាគ → **ចំណេះដឹងអំពីសិស្ស**

ពណ៌នាសូចនាករ → **១.២ ដឹងច្បាស់ពីប្រភេទគ្រួសារ និងកត្តាផ្សេងៗ**

សមត្ថភាព → **ពណ៌នាបានពីក្រុមជនជាតិ និងពិការភាពដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស**

**១.១ ស្គាល់សិស្ស (តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា និងឥរិយាបថសិក្សារបស់សិស្ស)**

- ពណ៌នាបានពីតម្រូវការសិក្សារបស់សិស្ស
- ពណ៌នាបានពីសមត្ថភាពសិក្សារបស់សិស្ស
- ពណ៌នាបានពីប្រវត្តិសិក្សារបស់សិស្ស
- ពណ៌នាបានពីឥរិយាបថសិក្សារបស់សិស្ស ។

**១.២ ដឹងច្បាស់ពីប្រភេទគ្រួសារ និងកត្តាផ្សេងៗ (ឧ.យេនឌ័រ សាវតារសង្គម សេដ្ឋកិច្ច ពិការភាព និង ក្រុមជនជាតិភាគតិច...) ដែលមានឥទ្ធិពលដល់ការសិក្សា របស់សិស្ស និង ដឹងពីរបៀបដោះស្រាយកត្តាទាំងនោះ**

- ពណ៌នាបានពី យេនឌ័រ ដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស
- ពណ៌នាបានពីកត្តាសង្គម សេដ្ឋកិច្ច ដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស
- ពណ៌នាបានពីក្រុមជនជាតិ និងពិការភាពដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស
- ពណ៌នាបានពីរបៀបដោះស្រាយកត្តាទាំងនោះ ។

## I. ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនជាអ្វី ?

តាមពិតការកំណត់បញ្ញត្តិ ឬការឱ្យនិយមន័យស្តង់ដារមានច្រើនណាស់ ។ ជួនកាលគេសរសេរពាក្យនៅក្នុងឈ្មោះផ្សេងគ្នា ប៉ុន្តែមានន័យដូចគ្នា។ ដូច្នេះ យើងកំណត់បញ្ញត្តិធំៗបីនៃស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនគឺ ÷

ក. ជាសេចក្តីអធិប្បាយសង្ខេប និងច្បាស់លាស់នូវទិដ្ឋភាពទាំងឡាយណាដែលគ្រូបង្រៀនត្រូវយល់ដឹង និងធ្វើ ។

ខ. ជាការបញ្ជាក់ប្រាប់ពីអំពើ ឬសកម្មភាពរបស់គ្រូបង្រៀនដែលអាចអនុវត្តបាន ហើយមានឥទ្ធិពលទៅលើសិស្ស។

គ. ជាឧបករណ៍សម្រាប់វាស់សមត្ថភាពដែលស្តែងចេញរបស់គ្រូបង្រៀន។

## II. គោលបំណង

ការកសាងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន គឺមិនមែនមានបំណងវាយតម្លៃសមត្ថភាពគ្រូបង្រៀន ដើម្បីចាត់ជាប្រភេទ គ្រូល្អ ឬគ្រូខ្សោយនោះទេ ពោលគឺយើងមានបំណងលើកស្ទួយការបង្រៀន និងរៀនរបស់គ្រូបង្រៀន សម្រាប់ជួយសម្រួលការសិក្សារបស់សិស្សឱ្យទទួលបានលទ្ធផលសិក្សាដែលមានកម្រិតសមស្របអាចទទួលយកបាន បើប្រៀបធៀបទៅនឹងស្តង់ដារកម្មវិធីសិក្សាចំណោះទូទៅ។ ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ជាឧបករណ៍ដ៏មានសារៈសំខាន់បំផុត និងជាខ្នាតគំរូសម្រាប់អ្នកអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូនិងសម្រាប់ធ្វើផែនការកសាងសមត្ថភាពគ្រូបង្រៀន។ ទៅអនាគតគេនឹងប្រើប្រាស់ស្តង់ដារសម្រាប់ចេញជាអាជ្ញាប័ណ្ណបង្រៀន និងជាលក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់ប្រាក់បៀវត្សដូចនៅប្រទេសអភិវឌ្ឍមួយចំនួន ។

## III. ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនមានផលប្រយោជន៍អ្វីខ្លះ?

ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនមានផលប្រយោជន៍សម្រាប់ ៖

- កែលំអការបង្រៀន និងរៀន
- ផ្តល់ចក្ខុវិស័យសម្រាប់បណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន
- កែលំអកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន
- រៀបចំផែនការអភិវឌ្ឍន៍សាលារៀន
- ធ្វើឱ្យគ្រូបង្រៀនមានលទ្ធភាព និងមានឱកាសជាច្រើនក្នុងការស្វែងរកសេវាការងារធ្វើទាំងក្នុងស្ថាប័នរដ្ឋ និងស្ថាប័នឯកជន
- បង្កើនសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនឱ្យប្រហាក់ប្រហែលប្រទេសក្នុងតំបន់
- ផ្តល់ជាមូលដ្ឋានគ្រឹះដើម្បីដំឡើងឋានន្តរសក្តិ ។

## ១. ចំណេះដឹងវិជ្ជាជីវៈ

គ្រូបង្រៀនមានចំណេះដឹងវិជ្ជាជីវៈសម្បូរបែប ។ គាត់ត្រូវតែដឹងច្បាស់ពីតម្រូវការសិក្សា សមត្ថភាពសិក្សា ប្រវត្តិសិក្សាច្បាស់លាស់ និងឥរិយាបថរបស់សិស្សម្នាក់ៗហើយក៏យល់ដឹងផង ដែរពីប្រភេទគ្រួសារ និងកត្តាផ្សេងៗ ដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស (យេនឌ័រ ពិការភាព និងក្រុមជនជាតិ ភាគតិច...) ព្រមទាំងយល់ដឹងពីវិធីដោះស្រាយកត្តាទាំងនេះ ។គ្រូបង្រៀនត្រូវមានការយល់ដឹងពីគោលនយោបាយអប់រំ ជាពិសេសគោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅហើយពេញចិត្តក្នុងការអនុវត្តនៅសាលារៀន ។ គ្រូបង្រៀនយល់ ពីទ្រឹស្តីក្នុងការរៀបចំកិច្ចតែងការបង្រៀន ដូចជា វត្ថុបំណង វិធីសាស្ត្របង្រៀន និងអាច ជ្រើសរើសវិធីវាយតម្លៃលទ្ធផលសិក្សាបានសមស្រប ។ គ្រូបង្រៀនយល់ពីខ្លឹមសារកម្មវិធីសិក្សា ហើយមានសមត្ថភាពពន្យល់មេរៀនបានច្បាស់លាស់ និងយល់ពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខ វិជ្ជាមួយទៅមុខវិជ្ជាមួយផ្សេងទៀត ក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្ត កាន់តែចង់រៀន ។

គ្រូបង្រៀនត្រូវយល់ពីបរិស្ថានអប់រំក្នុងថ្នាក់រៀន និងក្នុងសហគមន៍ ពិសេសយល់ពីរបៀបរៀនរបស់សិស្ស ភាពខុសគ្នារវាងទេពកោសល្យ ល្បឿន និងរបៀបសិក្សា ដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស ។

| ចំណេះដឹងអំពីសិស្ស | ១.១ ស្គាល់សិស្ស (តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា និងឥរិយាបថសិក្សារបស់សិស្ស) |
|---|---|
| | • ពណ៌នាបានពីតម្រូវការសិក្សារបស់សិស្ស<br>• ពណ៌នាបានពីសមត្ថភាពសិក្សារបស់សិស្ស<br>• ពណ៌នាបានពីប្រវត្តិសិក្សារបស់សិស្ស<br>• ពណ៌នាបានពីឥរិយាបថសិក្សារបស់សិស្ស ។ |

**១.២ ដឹងច្បាស់ពីប្រភេទគ្រួសារ និងកត្តាផ្សេងៗ (ឧ.យេនឌ័រ សាវតារសង្គម សេដ្ឋកិច្ច ពិការភាព និង ក្រុមជនជាតិភាគតិច...) ដែលមានឥទ្ធិពល ដល់ការសិក្សា របស់សិស្ស និងដឹងពីរបៀបដោះស្រាយកត្តាទាំងនោះ**

- ពណ៌នាបានពី យេនឌ័រ ដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស
- ពណ៌នាបានពីកត្តាសង្គម សេដ្ឋកិច្ច ដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស
- ពណ៌នាបានពីក្រុមជនជាតិ និងពិការភាពដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស
- ពណ៌នាបានពីរបៀបដោះស្រាយកត្តាទាំងនោះ ។

**១.៣ យល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ**

- ពណ៌នាបានពី គោលនយោបាយអប់រំជាតិ  គោលដៅអប់រំជាតិ និង គោលបំណងអប់រំចំណេះទូទៅ
- ពណ៌នាបានពី វិធីដែលធ្វើឱ្យបានសម្រេចគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និង គោលបំណងអប់រំចំណេះទូទៅ ។

**១.៤ យល់ដឹងពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀន**

- ពណ៌នាបានពីវត្ថុបំណង និងធាតុរបស់វាបានត្រឹមត្រូវ
- ពណ៌នាបានពីចំណុចសំខាន់ៗនៃគោលវិធីសិស្សមជ្ឈមណ្ឌល
- ពណ៌នាបានពីយុទ្ធវិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានសមស្រប
- ពណ៌នាបានពី សម្ភារបង្រៀន និងរៀនបានសមស្រប សម្រាប់ប្រើប្រាស់ក្នុងការបង្រៀនមេរៀន ។

## ចំណេះដឹងពីរបៀបរៀនរបស់សិស្ស

### ១.៥ យល់ដឹងពីខ្លឹមសារកម្មវិធីសិក្សា ហើយមានសមត្ថភាព ពន្យល់ និងបង្រៀនខ្លឹមសារមុខវិជ្ជាដែលមានក្នុងកម្មវិធីសិក្សាបានល្អ

- គូសបញ្ជាក់ពីខ្លឹមសារសំខាន់ៗ នៃកម្មវិធីសិក្សាដែលត្រូវបង្រៀនបានច្បាស់លាស់
- បង្រៀនដើម្បីបង្ហាញពីការយល់ខ្លឹមសារច្បាស់លាស់ ។

### ១.៦ យល់ដឹងពីរបៀបបញ្ជ្រាបខ្លឹមសារ ពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងទៀត ក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្តកាន់តែចង់រៀន

- ពណ៌នាបានពីវិធីបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅក្នុងមុខវិជ្ជាផ្សេងទៀត ដែលអាចជួយឱ្យសិស្ស រៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន ។

### ១.៧ យល់ដឹងពីបរិស្ថានសិក្សាក្នុងថ្នាក់រៀន និងសហគមន៍

- ពណ៌នាបានពី វិធីដែលធ្វើឱ្យប្រសើរឡើងនូវបរិស្ថានសិក្សាក្នុងថ្នាក់រៀន ដើម្បីជួយឱ្យសិស្សរៀនកាន់តែពូកែ
- ពណ៌នាបានពី វិធីដែលធ្វើឱ្យសហគមន៍សាលារៀន ចូលរួមជួយសិស្សឱ្យរៀនកាន់តែពូកែ ។

### ១.៨ យល់ដឹងពីរបៀបរៀនរបស់សិស្ស

- ពណ៌នាបានពីទ្រឹស្តីមួយ ឬច្រើននៃរបៀបរៀនរបស់សិស្ស
- ប្រាប់បានពីរបៀបរៀនផ្សេងៗគ្នារបស់សិស្ស ។

### ១.៩ យល់ដឹងពីភាពខុសគ្នានៃសម្បទា ល្បឿន និងរបៀបសិក្សារបស់សិស្ស

- ពន្យល់ពី ភាពខុសគ្នានៃសម្បទាសិក្សារបស់សិស្ស
- ពន្យល់ពីភាពខុសគ្នានៃល្បឿនសិក្សារបស់សិស្ស
- ពន្យល់ពីភាពខុសគ្នានៃរបៀបសិក្សារបស់សិស្ស ។

## ២. ការប្រតិបត្តិវិជ្ជាជីវៈ

គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀនឱ្យបានច្បាស់លាស់ប្រកបដោយប្រសិទ្ធភាព ស្របតាមកម្មវិធីសិក្សាដោយផ្អែកលើ សៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារសិក្សាផ្សេងៗទៀត ដែលអាចរកបាន។ ដើម្បីគាំទ្រដល់កិច្ចតែងការបង្រៀន គ្រូបង្រៀនត្រូវរៀបចំសម្ភារបង្រៀន និងរៀន ដើម្បីរិះរកមធ្យោបាយសម្រេចការសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធភាព ។ គ្រូបង្រៀនក៏ប្រើប្រាស់វិធីវាយតម្លៃលទ្ធផលសិក្សាផ្សេងៗគ្នា ដែលស្របទៅតាមតម្រូវការ និងទេពកោសល្យរបស់សិស្ស ។ គ្រូបង្រៀនត្រូវបញ្ជូនព័ត៌មានត្រឡប់ទៅ សិស្ស មាតាបិតា ឬអាណាព្យាបាល អំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស។

គ្រូបង្រៀនផ្តល់ឱ្យសិស្សគ្រប់រូប នូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យមានការប្រឹងប្រែងអស់ពីសមត្ថភាព ហើយលើកទឹកចិត្តសិស្សឱ្យកាន់តែមានការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន។ គ្រូបង្រៀនត្រូវចូលរួមក្នុងការអភិវឌ្ឍសាលារៀន ដើម្បីគាំទ្រការសិក្សា និងសុខុមាលភាពរបស់សិស្ស និងគ្រូបង្រៀនឯទៀត។

គ្រូបង្រៀនត្រូវចេះប្រើប្រាស់វិធីបង្រៀនឱ្យសម្បូរបែបដើម្បីសម្រួលដល់ការសិក្សារបស់សិស្ស និងសម្រេចបានវត្ថុបំណងមេរៀន ។ម្យ៉ាងទៀតគ្រូបង្រៀនគួរមានសមត្ថភាពផ្តល់ជាមធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្សតាមរយៈការអនុវត្តវិធីបង្រៀនសមស្របសម្បូរបែប ដោយបង្កឱកាសឱ្យសិស្សចូលរួមគិតបានល្អិតល្អន់និងដោយច្នៃប្រឌិត។ លើសពីនេះទៀត គ្រូបង្រៀនត្រូវចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យបើមានលទ្ធភាព ដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព។

ការរៀបចំផែនការ និងការពិនិត្យតាមដាន វាយតម្លៃលទ្ធផលសិក្សា

### ២.១ រៀបចំកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងការវាយតម្លៃ លទ្ធផលសិក្សាបានត្រឹមត្រូវ ហើយមានប្រសិទ្ធភាព

- កិច្ចតែងការបង្រៀនមានសេចក្ដីពណ៌នាបញ្ជាក់ ពីវត្ថុបំណងមេរៀនច្បាស់លាស់
- កិច្ចតែងការបង្រៀនមានសេចក្ដីពណ៌នាបញ្ជាក់ពី របៀបវាយតម្លៃ លទ្ធផលសិក្សាបានច្បាស់លាស់
- កិច្ចតែងការបង្រៀនមានសេចក្ដីពណ៌នាបញ្ជាក់ពី សកម្មភាពគ្រូ សិស្ស និងខ្លឹមសារមេរៀន  ដើម្បីគាំទ្រវត្ថុបំណងមេរៀនបានច្បាស់លាស់ និងត្រឹមត្រូវតាមគោលការណ៍ ។

### ២.២ រៀបចំសម្ភារបង្រៀន និងរៀន ដើម្បីធ្វើឱ្យការសិក្សាសម្រេច បានលទ្ធផលល្អ

- រៀបចំសម្ភាររៀនប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបានលទ្ធផលសិក្សា ល្អរបស់សិស្ស
- រៀបចំសម្ភារបង្រៀនប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបានលទ្ធផលសិក្សា ល្អរបស់សិស្ស ។

### ២.៣ ប្រើប្រាស់វិធីសមស្របសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សា របស់សិស្ស

- កសាងសំណួរតែស ដោយមានទម្រង់ និងរយៈពេលសមស្របសម្រាប់ សិស្សឆ្លើយ

- ជ្រើសរើសអាយតឹមតែស (Item Test) ពីសៀវភៅផ្សេងៗ ដែលមានទម្រង់សំណួរ និងរយៈពេលសមស្របសម្រាប់សិស្សឆ្លើយ
- បង្ហាញប្រាប់ពីអត្រាកំណែតែស និងការកែចម្លើយរបស់សិស្សបានត្រឹមត្រូវ
- កំណត់បានយ៉ាងច្បាស់ពី លទ្ធផលតែស ដើម្បីបង្ហាញពីប្រសិទ្ធភាពនៃការសិក្សារបស់សិស្ស ។

## ២.៤ តាមដានការចូលរួម និងថែរក្សាកំណត់ត្រានៃភាពរីកចម្រើនរបស់សិស្ស

- តាមដានការចូលរួមរបស់សិស្ស តាមរយៈការសង្កេត និងធ្វើកំណត់ត្រា
- ថែរក្សាកំណត់ត្រា ស្តីពីការចូលរួមរបស់សិស្សក្នុងសកម្មភាពសិក្សា ។

## ២.៥ ផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអាណាព្យាបាលសិស្ស អំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស

- ផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស តាមរយៈការនិយាយដោយផ្ទាល់ និងដាក់មូលវិចារណ៍សមស្របជា លាយលក្ខណ៍អក្សរ នៅលើសន្លឹកកិច្ចការរបស់សិស្ស ពិសេសលើសៀវភៅទំនាក់ទំនង
- ផ្តល់ព័ត៌មានត្រឡប់ទៅមាតាបិតាឬអាណាព្យាបាលសិស្សតាមរយៈរបាយការណ៍ ប្រចាំខែនិងទៅជួបផ្ទាល់ បើចាំបាច់ ។

### ២.៦ ផ្ដល់បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនអស់ពីលទ្ធភាព

- បង្ហាញឱ្យឃើញពីការគ្រប់គ្រងថ្នាក់រៀនមានប្រសិទ្ធភាព
- ជួយសិស្សឱ្យមានអន្តរកម្មវិជ្ជមានជាមួយសិស្សដទៃទៀត
- ផ្ដល់បរិស្ថានសិក្សាដែលធ្វើឱ្យសិស្សពង្រីកការសិក្សាបានច្រើន។

### ២.៧ ជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន

- បង្ហាញពីវិធីដែលអាចជួយសិស្សឱ្យមានការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួនកាន់តែខ្លាំង
- បង្ហាញកិច្ចការសិស្សជាឧទាហរណ៍ ដែលចង្អុលបង្ហាញការរៀនដោយខ្លួនឯង ( កិច្ចការសិស្ស គម្រោងតូចៗ របាយការណ៍ក្រុម ។ល។ ) ។

### ២.៨ ចូលរួមអភិវឌ្ឍន៍សាលារៀន ដើម្បីទ្រទ្រង់ការសិក្សា និងសុខុមាលភាពរបស់សិស្ស ព្រមទាំងសហសេវិក/មិត្តរួមអាជីព

- ពណ៌នាបានពីសកម្មភាពអភិវឌ្ឍសាលារៀនដែលគាត់បានចូលរួម
- លើកជាសំណួមពរពីសកម្មភាពអភិវឌ្ឍន៍សាលារៀន។

## ២.៩ ប្រើវិធីបង្រៀនផ្សេងៗ ដើម្បីជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចឱ្យបានតាមស្តង់ដារកម្មវិធីសិក្សារបស់ក្រសួង

- បង្ហាញពីវិធីបង្រៀនផ្សេងៗ ដូចជាអនុមានរួម អនុមានញែក ការងារក្រុម ពន្យល់បង្ហាញ ពីដំណោះស្រាយបញ្ហា ។ល។
- ពណ៌នាបានពី វិធីបង្រៀនដែលមានប្រសិទ្ធភាពចំពោះមេរៀននីមួយៗ ដែលបានប្រើពិសេសអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានត្រឹមត្រូវ
- ពន្យល់បានពីមូលហេតុដែលប្រើវិធីបង្រៀនទាំងនោះ ។

## ២.១០ ផ្តល់មធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្សតាមរយៈការអនុវត្តវិធីបង្រៀនសមស្រប និងសម្បូរបែប

- បង្ហាញពីវិធីបង្រៀនផ្សេងៗដែលផ្តល់ជាមធ្យោបាយឱ្យត្រូវទៅតាមរបៀបសិក្សារបស់សិស្សផ្សេងៗគ្នា (ឧ.ពូកែខាង ភាសា គណិត ចក្ខុ ចលនារាងកាយ តន្ត្រី ទាក់ទងរវាងបុគ្គល និងបុគ្គល ។ល ។)
- ពន្យល់បានពី វិធីបង្រៀនដែលផ្តល់ជាមធ្យោបាយ ឱ្យត្រូវទៅតាមរបៀបសិក្សាខុសៗ គ្នារបស់សិស្ស ។

## ២.១១ រៀបចំ និងផ្តល់ឱ្យសិស្ស នូវឱកាសសិក្សាពី ដំណោះស្រាយបញ្ហា ដើម្បីចូលរួមគិតឱ្យបានល្អិតល្អន់ និងដោយច្នៃប្រឌិត

- ជួយសិស្សឱ្យប្រើការគិតល្អិតល្អន់ ដើម្បីវិភាគចំណោទបញ្ហា
- ពណ៌នាបានពីរបៀប ដែលគាត់ប្រើការគិតដោយច្នៃប្រឌិត ដើម្បីដោះស្រាយបញ្ហា ។

### ២.១២ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ បើមានលទ្ធភាព ដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព

- ពណ៌នាបានពីរបៀបប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីជួយឱ្យសិស្សមានចិត្តចង់រៀន
- ពណ៌នាបានពីរបៀបដែលគាត់ប្រើប្រាស់ចំណេះដឹង និងបំណិនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដើម្បីឱ្យសិស្សរៀនកាន់តែមានប្រសិទ្ធភាព ។

## ៣. ការសិក្សាវិជ្ជាជីវៈ

យើងបានដឹងហើយថាគ្រូបង្រៀនគឺជាអ្នកលើកទឹកចិត្ត និងជាអ្នកធានាឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សា ។ ដូច្នេះគាត់ត្រូវតែស្វ័យសិក្សា វាយតម្លៃការបង្រៀន ដើម្បីអភិវឌ្ឍខ្លួនឯង និងប្រើប្រាស់ផែនការសម្រាប់ដឹកនាំស្វ័យសិក្សាមុខវិជ្ជាជីវៈជាប្រចាំស្របតាមជីវភាពរស់នៅជាក់ស្តែង ។ គ្រូបង្រៀនត្រូវអភិវឌ្ឍផ្នែកបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងបំណិនផ្សេងៗសម្រាប់អនុវត្តក្នុងការបង្រៀន ហើយធ្វើឱ្យប្រសើរឡើងនូវបំណិនទំនាក់ទំនងជាមួយ សិស្ស មាតាបិតា មិត្តរួមអាជីព និងជាមួយអ្នកផ្សេងៗទៀត នៅក្នុងសហគមន៍។ គ្រូបង្រៀនត្រូវលើកកម្ពស់កម្រិតសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនតាមរយៈការអាន និងស្រាវជ្រាវប្រភពឯកសារផ្សេងៗ ដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យកែលំអការបង្រៀន និងរៀន ហើយត្រូវមានទំនាក់ទំនងល្អជាមួយគ្រូដទៃទៀតក្នុងការសិក្សាវិជ្ជាជីវៈ ។

ស្វ័យសិក្សា

## ៣-១ វាយតម្លៃការបង្រៀន ការអភិវឌ្ឍខ្លួន និងការប្រើប្រាស់ផែនការសម្រាប់ដឹកនាំស្វ័យសិក្សាវិជ្ជាជីវៈបានទៀងទាត់

- កំណត់បានពីចំណុចខ្លាំង ចំណុចដែលត្រូវកែលំអ និងតម្រូវការក្នុងមុខវិជ្ជាជីវៈផ្ទាល់ខ្លួន
- រៀបចំផែនការអភិវឌ្ឍន៍វិជ្ជាជីវៈផ្ទាល់ខ្លួនប្រកបដោយប្រសិទ្ធភាព
- ស្វែងយល់ពីការប្រើប្រាស់សៀវភៅកំណត់ត្រាប្រចាំថ្ងៃ ដើម្បីឆ្លុះបញ្ចាំងការងាររបស់ខ្លួន។

## ៣-២ អភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ និងបំណិនសម្រាប់អនុវត្តក្នុងការបង្រៀន និងរៀន

- បង្កើនបំណិនដែលទាក់ទងនឹងវិជ្ជាជីវៈរបស់ខ្លួន ដោយបង្ហាញវិញ្ញាបនបត្រជាភស្តុតាង
- ពណ៌នាបានពីរបៀបប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ សម្រាប់ការស្រាវជ្រាវ និងរៀនដោយខ្លួនឯង
- មានឆន្ទៈស្វ័យសិក្សាស្រាវជ្រាវបំពេញបន្ថែមទាំងចំណេះដឹងមូលដ្ឋានទាំងបច្ចេកទេសបង្រៀនថ្មីៗ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។

ការចូលរួមកែលំអការបង្រៀន

### ៣-៣ ធ្វើឱ្យប្រសើរឡើង នូវបំណិនទំនាក់ទំនង ជាមួយសិស្ស មាតាបិតា មិត្តរួមអាជីព និងសហគមន៍

- បង្ហាញពីបំណិនទំនាក់ទំនងជាមួយសិស្ស
- បង្ហាញពីបំណិនទំនាក់ទំនងជាមួយសហការី
- បង្ហាញពីបំណិនទំនាក់ទំនងជាមួយមាតាបិតា និងសហគមន៍ ។

### ៣-៤ អានអត្ថបទវិជ្ជាជីវៈគ្រូបង្រៀន និងស្រាវជ្រាវ ដើម្បីពង្រីកចំណេះដឹង ឱ្យបានទូលំទូលាយក្នុងន័យធ្វើឱ្យការបង្រៀនកាន់តែប្រសើរឡើង

- ពណ៌នាបានពីអត្ថបទដែលគាត់បានអាន និងស្រាវជ្រាវហើយយកបទពិសោធ ក្នុងអត្ថបទនោះមក ជួយកែលំអការបង្រៀន
- ធ្វើផ្ទាក់និទស្សន៍ដើម្បីបង្ហាញបទពិសោធដែលទទួលបានពីការអាន និងស្រាវជ្រាវ ឯកសារផ្សេងៗ ដល់មិត្តរួមអាជីព ដើម្បីបង្កើនសមត្ថភាព ។

### ៣-៥ ធ្វើអន្តរកម្មជាមួយគ្រូដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈផ្សេងៗ

- ធ្វើបញ្ជីឈ្មោះសិក្ខាសាលា ឬវគ្គបំប៉នផ្សេងៗ ដែលបានចូលរួម
- ពន្យល់បានពីខ្លឹមសារសិក្ខាសាលា ឬវគ្គបំប៉នដែលបានចូលរួម ហើយបានផ្តល់បទ ពិសោធល្អៗ ដល់ការបង្រៀន និងរៀន ។

## ៤. សីលធម៌វិជ្ជាជីវៈ

សីលធម៌វិជ្ជាជីវៈ គឺពាក់ព័ន្ធទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់ក្នុងវិជ្ជាជីវៈគ្រូបង្រៀនដែលជារួមមានការប្ដេជ្ញាចិត្តបង្រៀនសិស្សប្រើប្រាស់មនសិការវិជ្ជាជីវៈប្រកបដោយគតិបណ្ឌិត និងមានចំណេះដឹងគ្រប់គ្រាន់តាមក្រមសីលធមិ វិជ្ជាជីវៈគ្រូបង្រៀន និ ងច្បាប់ស្ដីពីការអប់រំ ។

គ្រូបង្រៀនត្រូវគោរពពេលវេលាតាមភារកិច្ច មានវត្តមានជាប្រចាំនៅក្នុងសាលារៀន មានការស្លៀកពាក់សមរម្យ និងមានឥរិយាបថថ្លៃថ្នូរ ។ គាត់គួរតែចូលរួមក្នុងគ្រប់សកម្មភាពទាំងក្នុងនិងក្រៅម៉ោងទាំងអស់របស់សាលារៀនឱ្យបានសមស្របតាមករណីដែលអាចធ្វើបាន ។

គ្រូបង្រៀនមានប្រសិទ្ធភាព គឺមិនរើសអើងសិស្ស ទោះនៅក្នុងកាលៈទេសៈណាក៏ដោយដូចជាបញ្ហាយេនឌ័រ ជនជាតិភាគតិច ពិការភាព ក្រីក្រ និងត្រូវចេះថែទាំសិស្ស ផ្ដល់លទ្ធភាពឱ្យសិស្សប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាព ហើយយកចិត្តទុកដាក់ដល់សិស្សឱ្យបានស្មើៗគ្នារួចបង្ហាញពីភាពយុត្តិធមិក្នុងការត្រួតពិនិត្យលទ្ធផលសិក្សា ។ នៅពេលទាក់ទងជាមួយសិស្សគ្រូបង្រៀនត្រូវមានការគោរពសិស្សដោយមិននិយាយមើលងាយ ឬដាក់ទណ្ឌកម្មពួកគេតាមរបៀបហឹង្សាឡើយ ។ គ្រូបង្រៀនប្រកាន់ចរិយាសម្បត្តិមានសុជីវធមិ និងអាកប្បកិរិយាថ្លៃថ្នូរសម្រាប់ធ្វើការសហការជាមួយសហការី និងមាតាបិតាសិស្ស ដើម្បីផលប្រយោជន៍សិស្សផ្ដល់ជាគំរូដល់សិស្សក្នុងការរស់នៅ និងរៀនសូត្របានល្អ ពិសេសចេះលើកកម្ពស់ស្មារតីសិស្សឱ្យរឹងប៉ឹង និងវិជ្ជមានហើយបង្កើតស្មារតីលះបង់ និងការរួមចំណែកចំពោះ សហគមន៍ទាំងមូល ។

## ៤.១ បង្ហាញពីការយកចិត្តទុកដាក់ និងថែរក្សាសិស្សហើយជានិច្ចកាលធ្វើការ ដើម្បីប្រយោជន៍សិស្ស និងសង្គម

- និយាយទៅកាន់សិស្ស សហការី និងអ្នកឯទៀតនៅក្នុងសហគមន៍ដោយមានការគោរព និងលើកទឹកចិត្ត
- បង្ហាញពីការគោរពសិទ្ធិកុមារមិនត្រូវនិយាយមើលងាយ ឬដាក់ពិន័យសិស្សតាមរបៀបអំពើហិង្សា
- ធ្វើការជាមួយសហការី និងសមាជិកសហគមន៍ឯទៀតដើម្បីប្រយោជន៍សិស្ស ។

## ៤.២ បង្ហាញពីការប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់

- ទៅថ្នាក់រៀន និងចូលរួមព្រឹត្តិការណ៍ផ្សេងៗបានទៀងទាត់ និងទាន់ពេលវេលា
- បង្ហាញពីអាកប្បកិរិយារាក់ទាក់ និងសប្បុរសធម៌
- បង្ហាញពីការគោរពសិស្ស សហការី និងអ្នកឯទៀតក្នុងសហគមន៍
- បង្ហាញពីអារម្មណ៍ជក់ចិត្ត និងគំនិតផ្តួចផ្តើមលើគ្រប់ទិដ្ឋភាពនៃសកម្មភាពវិជ្ជាជីវៈ
- បង្ហាញពីចំណេះដឹងលើក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងច្បាប់ស្តីពីការអប់រំ ។

## ៤.៣ បង្ហាញអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌ និងមានទំនាក់ទំនងដោយសុខដុម ជាមួយ សិស្ស និងសហគមន៍

- ស្លៀកពាក់សមរម្យ
- បង្ហាញពីអារម្មណ៍វិជ្ជមានចំពោះសិស្ស និងអ្នកឯទៀត
- បង្ហាញពីសមត្ថភាព ដើម្បីរក្សាទំនាក់ទំនងប្រកបដោយសុខដុម
- ផ្តល់តម្លៃសីលធម៌ទៅមាតាបិតាសិស្ស និងអ្នកឯទៀត ។

### ៤.៤ ប្រើប្រាស់ភាពយុត្តិធម៌ និងតម្លាភាព ក្នុងការប្រព្រឹត្តជាមួយសិស្ស សហសេវិក និង សមាជិកផ្សេងៗរបស់សហគមន៍

- បង្ហាញពីការស្មោះត្រង់ក្នុងមុខវិជ្ជាជីវៈដោយសំដែងនូវសុភាវធម៌ និងភាពមិនលំអៀង
- ផ្តល់ឱកាសដល់សិស្សគ្រប់រូបមានលទ្ធភាពទទួលបាននូវពេលវេលា និងធនធានស្មើៗគ្នា ដោយមិនគិតពីភេទ ជនជាតិភាគតិច ឬអ្នកក្រីក្រ និងពិការភាព
- វាយតម្លៃលទ្ធផលសិក្សាប្រកបដោយយុត្តិធម៌ ។